**ឧបសម្ព័ន្ធនៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៣**
**ស្តីពីការដាក់ឲ្យអនុវត្តបទដ្ឋានអប្បបរមា**
**ស្តីពីកិច្ចសន្យាសេវាការងារឲ្យធ្វើនៅបរទេស**

# បទដ្ឋានអប្បបរមា
# ស្តីពី
# កិច្ចសន្យាសេវាកការងារឲ្យធ្វើនៅបរទេស

កិច្ចសន្យានេះធ្វើឡើងរវាង

ក្រុមហ៊ុន ........................................................................................................ អាសយដ្ឋាន ផ្ទះលេខ..........ផ្លូវ............ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ/ក្រុង.............. ខេត្ត/រាជធានី..............................ព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានការអនុញ្ញាតតាម ប្រកាសលេខ.................... ចុះថ្ងៃទី.......... ខែ......... ឆ្នាំ............ មានលោក/លោកស្រី ............................................ មានតួនាទី/ភារកិច្ចជា........................................ ជាអ្នក តំណាង ចាប់ពីពេលនេះតទៅ ហៅថា «**ភាគីទីភ្នាក់ងារជ្រើសរើសឯកជន**»

និង

លោក/លោកស្រីឈ្មោះ ........................................................ អាយុ..............ឆ្នាំ សញ្ជាតិខ្មែរ ដែលមាន ................................................................................................ ............................................................................................................................ ជាឯកសារសំគាល់អត្តសញ្ញាណ។ អាសយដ្ឋាន ផ្ទះលេខ...........ផ្លូវ..............ក្រុម............... ភូមិ.........................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ/ក្រុង................. ខេត្ត/រាជធានី ..............................ព្រះរាជាណាចក្រកម្ពុជា ចាប់ពីពេលនេះតទៅ ហៅថា «**ភាគីពលករ**»។

ភាគីទាំងពីរ បានឯកភាព និងព្រមព្រៀងគ្នា ដូចតទៅ ៖

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

ប្រការ១.-

សេវាកការងារឲ្យធ្វើនៅបរទេសគឺជាប្រព័ន្ធសេវាដែល **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** រ៉ាប់រងធ្វើដោយត្រូវធានាឲ្យបានថា **ភាគីពលករ** ដែលជាអ្នកប្រើសេវាទាំងឡាយនោះទទួល

បានការងារសមរម្យដូចជាលក្ខខណ្ឌការងារល្អធ្វើនៅប្រទេស ............................ ស្របតាមច្បាប់ និងបទបញ្ញារបស់ព្រះរាជាណាចក្រកម្ពុជា និងរបស់ប្រទេស ...................................។ ការងារដែលពលករត្រូវធ្វើមានឈ្មោះថា .................................. ដែលពលករត្រូវទទួលបានប្រាក់ឈ្នួលជាមូលដ្ឋានចំនួន............... (សរសេរជាលេខ និងជាអក្សរ)................................. ..................ក្នុងមួយខែៗ។ ប្រាក់ឈ្នួលនេះមិនត្រូវទាបជាងប្រាក់ឈ្នួលអប្បបរមានៃប្រទេស ........................................ ដែលជាប្រទេសទទួលទេ។

ប្រការ២.-

ក្នុងការផ្ដល់សេវារកការងារឲ្យធ្វើនៅបរទេស **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** សន្យាអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និង កិច្ចសន្យា រវាង **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** និង **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** ចុះថ្ងៃទី..........ខែ............ ឆ្នាំ...............។

ប្រការ៣.-

ក្នុងការទទួលប្រើប្រាស់សេវារកការងារឲ្យធ្វើនៅបរទេស **ភាគីពលករ** សន្យាអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិទាំងឡាយនៃកិច្ចសន្យាសេវារកការងារឲ្យធ្វើនៅបរទេស ដោយ **ភាគីពលករ** ត្រូវបង់រាល់ការចំណាយទាំងអស់ដែលជាបន្ទុករបស់ភាគីពលករ ស្របតាមការកំណត់ក្នុងប្រការខាងក្រោមជាបន្តបន្ទាប់។ នៅពេលចុះកិច្ចសន្យាសេវារកការងារឲ្យធ្វើនៅបរទេស **ភាគីពលករ** ត្រូវតែបានពិនិត្យយល់ច្បាស់លាស់ និងស្ម័គ្រចិត្តទទួលយល់ព្រមលើគ្រប់លក្ខខណ្ឌទាំងអស់នៃ **កិច្ចសន្យាការងារ** ដែលនឹងត្រូវអនុវត្តនៅប្រទេសទទួល ដោយ **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** ត្រូវធ្វើឲ្យមានកិច្ចសន្យាការងារ ជាភាសាខ្មែរ សម្រាប់ **ភាគីពលករ** អានជាមុន។

## ផ្នែកទី២
## ភារកិច្ចរបស់ភាគីទីភ្នាក់ងារជ្រើសរើសឯកជន

ប្រការ៤.-

**ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** មានភារកិច្ចដូចខាងក្រោម ៖

- ត្រូវផ្ដល់ព័ត៌មានទាំងឡាយទាក់ទងនឹងលក្ខខណ្ឌការងារ និង លក្ខខណ្ឌរស់នៅរបស់ **ភាគីពលករ** ដែលត្រូវធ្វើនៅបរទេស ដោយត្រឹមត្រូវ និងគ្រប់គ្រាន់ ទាំងភាពងាយស្រួល និងការលំបាក

- ត្រូវចាត់ចែង និងរៀបចំក្នុងការទាក់ទងជាមួយក្រុមគ្រួសារ ស្នាក់នៅ ហូបចុក និងស្លៀកពាក់ (កំណត់ដោយក្រុមហ៊ុន) ឲ្យបានសមរម្យ ដែលរក្សាបាននូវលក្ខខណ្ឌសុខភាព អនាម័យ សុវត្ថិភាព និងសិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ សម្រាប់ **ភាគីពលករ** ជាពិសេសស្ត្រី នៅក្នុងរយៈពេលនៃវគ្គអប់រំណែនាំតម្រង់ទិស និងបណ្តុះបណ្តាល មុនពេលចេញដំណើរ
- ត្រូវផ្តល់ការអប់រំ ណែនាំតម្រង់ទិស និងបណ្តុះបណ្តាលមុនពេលចេញដំណើរដល់ **ភាគីពលករ** ឲ្យបានច្បាស់លាស់ និងគ្រប់គ្រាន់ ទាំងខាងភាសា ទំនៀមទំលាប់រស់នៅ លក្ខខណ្ឌការងារដែលត្រូវធ្វើ ជំនាញដែលពលករត្រូវមាន សម្រាប់ធ្វើការងារ ខ្លឹមសារនៃកិច្ចសន្យាការងារ និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង ច្បាប់ផ្សេងទៀតដែលទាក់ទង អនាម័យនិងសុវត្ថិភាពការងារ ការថែទាំសុខភាព ការការពារនិងបង្ការជំងឺឆ្លងមួយចំនួន ដូចជាជំងឺអេដស៍ជាដើម ដោយស្របតាមគោលការណ៍
- ណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រាល់ការអប់រំ ណែនាំតម្រង់ទិស និងបណ្តុះបណ្តាលមុនពេលចេញដំណើរ ត្រូវឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ
- ក្នុងរយៈពេលវគ្គបណ្តុះបណ្តាល ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវផ្តល់ព័ត៌មានពីទីកន្លែងរបស់ក្រុមហ៊ុន ហើយពលករមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការចេញចូល
- ត្រូវផ្តល់អាសយដ្ឋានសម្រាប់ទាក់ទងសំខាន់ៗដល់ **ភាគីពលករ** ដូចជាស្ថានឯកអគ្គរាជទូត ឬ ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅប្រទេសទទួលពលករ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារដៃគូ ស្ថាប័នមានសមត្ថកិច្ច និងដៃគូពាក់ព័ន្ធសំខាន់ៗ ក៏ដូចជាការណែនាំឲ្យបានយល់ និងចងចាំច្បាស់លាស់អំពីរបៀបរបប និងនីតិវិធីនៃការដោះស្រាយវិវាទ នៅពេលដែលវិវាទកើតឡើងជាដើម
- ត្រូវចាត់ចែងរៀបចំការពិនិត្យសុខភាពពលករ ទៅតាមការកំណត់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសទទួលពលករ។ រាល់លទ្ធផលនៃការពិនិត្យ ត្រូវបានរក្សាជាការសំងាត់
- ត្រូវរៀបចំចាត់ចែងធ្វើរាល់ឯកសារផ្លូវច្បាប់ត្រឹមត្រូវ និងគ្រប់គ្រាន់សម្រាប់ពលករចូលទៅស្នាក់នៅ និងធ្វើការងារនៅប្រទេសទទួលពលករ ដូចជាការធ្វើកិច្ចសន្យាការងារ ប័ណ្ណអនុញ្ញាតធ្វើការងារ លិខិតឆ្លងដែន ទិដ្ឋាការចូលទៅធ្វើការងារ ឯកសារធ្វើដំណើរជាដើម ដោយថតចម្លងឯកសារទាំងនោះចំនួនមួយច្បាប់ជូនពលករ។ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវពិនិត្យមើលឡើងវិញឲ្យបានដឹងថា ពលករបានយល់ដឹងរួចហើយ អំពីឯកសារទាំងអស់នេះនៅមុនពេលចេញដំណើរ
- ត្រូវធានាថា កិច្ចសន្យាការងារដែលបានចុះហត្ថលេខាដោយនិយោជក ត្រូវបានបញ្ជូនមកឲ្យពលករពិនិត្យ និងចុះហត្ថលេខានៅក្នុងប្រទេសកម្ពុជាមុននឹងចេញដំណើរ

•••

- ត្រូវជូនដំណើរពលករ និងត្រូវដាក់ឲ្យពលករធ្វើការងារជាមួយនិយោជក នៅប្រទេសទទួល ដែលពលករបានចុះកិច្ចសន្យាការងារជាមួយឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ស្របតាមកិច្ចសន្យាការងារ និងច្បាប់ប្រទេសទទួល
- ត្រូវទទួលបន្ទុកក្នុងការចំណាយ និងត្រូវយកចិត្តទុកដាក់ដល់ពលករ ជាពិសេសស្ត្រី ក្នុងករណីពលករទៅដល់ប្រទេសទទួល ហើយមានការរង់ចាំដើម្បីទៅដល់ទីកន្លែងធ្វើការ ដែលរយៈពេលនៃការរង់ចាំនេះ មិនលើសពី ០៥ថ្ងៃ នៃថ្ងៃធ្វើការ ហើយប្រសិនបើលើសរយៈពេលនេះ ពលករត្រូវទទួលបានប្រាក់ឈ្នួល និងរាល់ការចំណាយជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសឯកជន។ ការចំណាយទាំងនេះ មិនត្រូវឲ្យពលករសង ឬ កាត់ប្រាក់ឈ្នួលពីពលករវិញឡើយ។
- ត្រូវចាត់ចែងឲ្យពលករទទួលបានប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតត្រឹមត្រូវ និងទាន់ពេល ដូចដែលបានកំណត់នៅក្នុងកិច្ចសន្យាការងារ និងបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ជានៃប្រទេសទទួល។ ត្រូវរៀបចំឲ្យមានប្រព័ន្ធនៃការរក្សាទុក និងផ្ទេរប្រាក់ដ៏ត្រឹមត្រូវ
- ត្រូវឃ្លាំមើលជាប្រចាំនូវលក្ខខណ្ឌការងារ ទំនាក់ទំនងវិជ្ជាជីវៈ លក្ខខណ្ឌនៃការរស់នៅ និងបញ្ហាផ្សេងៗ ដែលនឹងអាចកើតមានឡើងចំពោះពលករក្នុងកំឡុងពេលបំពេញការងារតាមកិច្ចសន្យា។ ការឃ្លាំមើលជាប្រចាំនេះត្រូវយកចិត្តទុកដាក់ចំពោះពលករដែលធ្វើការនៅដាច់ពីគេ។ ក្នុងករណីពលករមានបញ្ហាដូចជា គ្រោះថ្នាក់ ឬ ជំងឺធ្ងន់ធ្ងរ ឬ បាត់ខ្លួន ឬ មានវិវាទការងារ ទីភ្នាក់ងារត្រូវស្វែងរកអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នជំនាញ ដើម្បីដោះស្រាយបញ្ហាឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- ត្រូវជួយការពារ ដោះស្រាយ និងស្វែងរកសេវាជំនួយផ្នែកច្បាប់ ដើម្បីជាប្រយោជន៍របស់ពលករ ក្នុងករណីពលករបានយល់ថាមានការរំលោភបំពាន កេងប្រវ័ញ្ចជួញដូរ ឬ បាត់ខ្លួននៅក្នុងពេលម៉ោងបណ្ដុះបណ្ដាលមុនចេញដំណើរ និង នៅពេលធ្វើការតាមកិច្ចសន្យាការងារ
- ត្រូវរកសេវាជំនួយផ្នែកច្បាប់ជូនពលករ នៅពេលដែលកើតមានវិវាទការងារ នៅពេលធ្វើការងារតាមកិច្ចសន្យាការងារ ហើយដែលវិវាទនោះមិនអាចដោះស្រាយបានដោយការចរចា ឬ ការផ្សះផ្សា ឬ ការសម្របសម្រួល
- ត្រូវជួយអន្តរាគមន៍ ក្នុងករណីដែលឯកសារផ្ទាល់ខ្លួនរបស់ពលករត្រូវបានដកហូតដោយខុសច្បាប់
- ត្រូវជួយសម្របសម្រួលបន្តកិច្ចសន្យាការងារជាថ្មី នៅក្នុងករណីដែលពលករត្រូវបន្តកិច្ចសន្យាការងារ
- ត្រូវប្រគល់ជូន **នាគីពលករ** នូវឯកសារច្បាប់ដើមវិញ នៅពេលណាដែលភ្នាក់ងារជ្រើសរើសឯកជន បានរៀបចំឯកសារស្របច្បាប់សម្រាប់ពលករបានរួចរាល់
- ត្រូវជួយចាត់ចែងមាតុភូមិនិវត្តន៍របស់ពលករឲ្យបានដល់គោលដៅ ប្រកបដោយសុវត្ថិភាព និងទទួលបានសិទ្ធិ និងផលប្រយោជន៍ ស្របតាមច្បាប់ និងបទបញ្ជា។

...

## ផ្នែកទី៣
## កាតព្វកិច្ចរបស់ភាគីពលករ

ប្រការ៥.-

**ភាគីពលករ** មានកាតព្វកិច្ចដូចខាងក្រោម ៖

- ពលករត្រូវមានអាយុពី១៨ឆ្នាំឡើង យោងទៅលើឯកសារផ្ទាល់ខ្លួន ស្របច្បាប់ គ្រប់គ្រាន់ និងត្រឹមត្រូវដែលត្រូវប្រគល់ជូន **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** សម្រាប់ការរៀបចំរាល់ឯកសារតាមច្បាប់ និងបទបញ្ញានានារបស់ស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសទទួលពលករ
- ត្រូវពិនិត្យឲ្យបានច្បាស់លាស់ លើខ្លឹមសារនៃកិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងារ ដូចជា លក្ខខណ្ឌនៃការរស់នៅ លក្ខខណ្ឌការងារ ស្ថានភាពការងារ ប្រភេទការងារ ផលប្រយោជន៍ដែលទទួលបាន និងអាសយដ្ឋានដែលត្រូវធ្វើការទំនាក់ទំនងជាដើម មុននឹងសម្រេចចិត្តចុះហត្ថលេខាលើកិច្ចសន្យានោះ។ សាមីពលករមានសិទ្ធិទទួលយកជនណាម្នាក់ដែលខ្លួនទុកចិត្តឲ្យចូលរួមក្នុងការពិនិត្យ មុននឹងធ្វើការចុះហត្ថលេខាលើកិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងារ
- ត្រូវធ្វើការងារជូនតែនិយោជក ដែលខ្លួនបានចុះកិច្ចសន្យាការងារជាមួយតែប៉ុណ្ណោះ ដោយមិនអាចធ្វើការងារជូននិយោជកណាមួយផ្សេងទៀតឡើយ នៅក្នុងរយៈពេលនៃកិច្ចសន្យាការងារ។ ក្នុងករណីពលករចង់ផ្លាស់ប្តូរនិយោជក លុះត្រាតែធ្វើការពិភាក្សាឯកភាពជាមួយ **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** ស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ញានៃប្រទេសទទួល
- ត្រូវរាយការណ៍ជូនក្រុមហ៊ុន ឬ ស្ថានឯកអគ្គរាជទូត ឬ ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ បើសិនពលករមានវិវាទ
- ត្រូវទទួលខុសត្រូវចំណាយលើឯកសារ សំបុត្រយន្តហោះ ឬ ថ្លៃធ្វើដំណើរត្រឡប់មកមាតុភូមិ ក្នុងករណីពលករបញ្ចប់កិច្ចសន្យាមុនកំណត់ដោយមូលហេតុផ្ទាល់ខ្លួន
- ត្រូវជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសរបស់ខ្លួន នៅពេលដែលចង់បន្តកិច្ចសន្យាការងារជាថ្មីជាមួយនិយោជក ដើម្បីឲ្យទីភ្នាក់ងារជ្រើសរើសរៀបចំឯកសារបន្តកិច្ចសន្យាស្របច្បាប់ ដោយពលករត្រូវបង់រាល់ចំណាយទាំងឡាយ ដែលជាបន្ទុករបស់ខ្លួន
- ត្រូវបង់អាករ និងធ្វើកាតព្វកិច្ចផ្សេងៗ ស្របតាមការកំណត់របស់ច្បាប់ និងបទបញ្ញានានារបស់ប្រទេសទទួលពលករ

- ត្រូវបង់ប្រាក់សម្រាប់ចំណាយក្នុងការធ្វើឯកសារផ្ទាល់ខ្លួន។ ការចំណាយនេះមិនរាប់បញ្ចូលសេវាផ្សេងៗដែលផ្តល់ឲ្យដោយទីភ្នាក់ងារជ្រើសរើសឯកជនទេ
- ត្រូវគោរពច្បាប់ និងបទបញ្ញាផ្សេងៗនៃប្រទេសទទួលពលករ។

## ផ្នែកទី៤
## ការអនុវត្តកិច្ចសន្យា

ប្រការ៦.-

ក្នុងករណី **ភាគីពលករ** មិនគោរពកិច្ចសន្យា បណ្តាលឲ្យមានការខូចខាតដល់ **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** **ភាគីពលករ** ត្រូវទទួលខុសត្រូវជួសជុលសងការខូចខាតទាំងនោះដល់ **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន**។

ប្រការ៧.-

ក្នុងករណី **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** មិនគោរពកិច្ចសន្យា បណ្តាលឲ្យមានការខូចខាតដល់ **ភាគីពលករ** **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** ត្រូវទទួលខុសត្រូវជួសជុលសងការខូចខាតទាំងនោះដល់ **ភាគីពលករ**។

ប្រការ៨.-

ក្នុងករណីមានវិវាទកើតឡើងពីការអនុវត្តកិច្ចសន្យា ភាគីនីមួយៗត្រូវដោះស្រាយគ្នាតាមរយៈការផ្សះផ្សាតាមនីតិវិធីជាមុន។ ក្នុងករណីមិនអាចដោះស្រាយគ្នាតាមរយៈការផ្សះផ្សាបាន ភាគីម្ខាងមានសិទ្ធិដាក់ពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ឬ តុលាការ។

ប្រការ៩.-

ក្នុងករណីភាគីណាមួយចង់រំលាយកិច្ចសន្យានេះ ភាគីនោះត្រូវជូនដំណឹងទៅភាគីម្ខាងទៀត និងត្រូវសងការខូចខាតពីការរំលាយកិច្ចសន្យារបស់ខ្លួន។

## ផ្នែកទី៥
## អវសានប្បញ្ញត្តិ

ប្រការ១០.-

គ្រប់បទប្បញ្ញត្តិទាំងឡាយរបស់កិច្ចសន្យានេះ អាចធ្វើការផ្លាស់ប្តូរ ឬ កែប្រែទៅបានលុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ និងត្រូវមានការឯកភាពពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ប្រការ១១.-

ក្នុងករណីប្រធានសក្តិ ធ្វើឲ្យភាគីណាមួយមិនអាចអនុវត្តកិច្ចសន្យាបាន កិច្ចសន្យាត្រូវបញ្ចប់ជាស្ថាពរ ហើយភាគីនីមួយៗមិនមានជាប់កាតព្វកិច្ចឡើយ។

ប្រការ១២.-

ក្នុងករណីដែលភាគីណាមួយនៃកិច្ចសន្យា មានធុរៈយ៉ាងធ្ងន់ធ្ងរ ដែលមានហេតុផល ឬ ភស្តុតាងសមស្របជាក់ស្តែង ជាហេតុនាំឲ្យភាគីនោះមិនអាចបន្តអនុវត្តកិច្ចសន្យាបាន ឬ ត្រូវធ្វើការផ្លាស់ប្តូរ ឬ កែប្រែកិច្ចសន្យានេះ ភាគីនោះត្រូវជូនដំណឹងជូនទៅភាគីម្ខាងទៀត ដើម្បីធ្វើការពិភាក្សាឲ្យបានឯកភាពគ្នាជាមុន មុននឹងធ្វើការផ្លាស់ប្តូរ ឬ កែប្រែ ឬ ធ្វើកិច្ចសន្យាថ្មីជំនួសឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ប្រការ១៣.-

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាភាសាខ្មែរ ចំនួន ០៣ ច្បាប់ដើម ដោយត្រូវបានប្រគល់ឲ្យ និងរក្សាទុកនៅ **ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** ចំនួន ០១ ច្បាប់ នៅ **ភាគីពលករ** ចំនួន ០១ ច្បាប់ និងនៅនាយកដ្ឋានមុខរបរ និង ហត្ថពលកម្មនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០១ ច្បាប់។

ដើម្បីជាសក្ខីភាពនៃការព្រមព្រៀងគ្នានេះ ភាគីទាំងពីរ បានពិនិត្យ និង បានអានឡើងវិញនូវគ្រប់ប្រការនៃកិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងារ ហើយភាគីទាំពីរបានស្ម័គ្រចិត្តចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃរៀងៗខ្លួន ដោយមិនមានការបង្ខិតបង្ខំណាមួយឡើយ នៅថ្ងៃទី..........ខែ............ឆ្នាំ.................. ដោយភាគីនីមួយៗមានសាក្សីម្នាក់រៀងៗខ្លួនបានផ្តិតស្នាមមេដៃទទួលដឹងឮផងដែរ។

| | |
|---|---|
| **ហត្ថលេខា និងត្រា**<br>**ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** | **ស្នាមមេដៃ**<br>**ភាគីពលករ** |
| **សាក្សី**<br>**របស់ភាគីទីភ្នាក់ងារជ្រើសរើសឯកជន** | **សាក្សី**<br>**របស់ភាគីពលករ** |

*ការចុះបញ្ជិកា*

*របស់នាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម*

*ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

...